**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

៣✵៨

**ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា**

លេខ ១៦៣៣ ស.អ.យ.

រាជធានីភ្នំពេញ, ថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ ២០១២

# ប្រកាស

## ស្តីពី

## ការកែសម្រួល និងបំពេញបន្ថែមសមាសភាព និងតួនាទី ភារកិច្ច របស់ក្រុមការងារថ្នាក់ជាតិពហុវិស័យស្តីពីកុមារកំព្រា និងកុមារងាយរងគ្រោះ

៣✵៨

## រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ ន.ស/រ.ក.ត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/ស.ន/ ៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃ គណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ន.ស/រ.ក.ម/០១០៥/០០១ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើត ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ.បក. ចុះថ្ងៃទី២៤ ខែមិនា ឆ្នាំ២០១១ របស់រាជរដ្ឋាភិបាលកម្ពុជា ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ របស់ក្រសួង សង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- បានឃើញព្រះរាជក្រឹត្យលេខ ន.ស/រ.ក.ត/១២០៩/១២០១ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០០៩ស្តីពី ការបង្កើតក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ
- បានឃើញផែនការយុទ្ធសាស្ត្រជាតិទូលំទូលាយនិងពហុវិស័យឆ្លើយតបការរីករាលដាលមេរោគអេដស៍ និងជំងឺអេដស៍របស់ អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍លើកទី៣( ២០១១-២០១៥)
- បានឃើញប្រកាសលេខ២១៧ ស.អ.យ ចុះថ្ងៃទី២៦ខែមេសាឆ្នាំ២០០៦ របស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា ស្តីពីការដាក់ឲ្យអនុវត្តគោលនយោបាយស្តីពីការថែទាំជំនួសចំពោះកុមារ
- បានឃើញប្រកាសលេខ២២៨០ ស.អ.យ ចុះថ្ងៃទី១១ ខែតុលា ឆ្នាំ២០១១ របស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ស្តីពីនីតិវិធីអនុវត្ត គោលនយោបាយស្តីពីការថែទាំជំនួសចំពោះកុមារ
- យោងកម្មវិធីការងារ របស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាសម្រាប់ឆ្នាំ២០០៨-២០១៣
- យោងលិខិតរបស់ក្រសួង ស្ថាប័ន អង្គការពាក់ព័ន្ធ ចាត់តាំងមន្ត្រីចូលរួមក្នុងក្រុមការងារថ្នាក់ជាតិពហុវិស័យស្តីពីកុមារកំព្រា និងកុមារងាយរងគ្រោះ។



ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា អគារលេខ ៧៨៨ មហាវិថីព្រះមុនីវង្ស រាជធានីភ្នំពេញ, ទូរស័ព្ទ/ទូរសារ : (៨៥៥) ២៣ ៧២៦០៨៦
Ministry of Social Affairs, Veterans and Youth Rehabilitation, #788, Monivong Blvd., Phnom Penh, Cambodia. Fax/Phone: (855) 23 726 086

# សម្រេច

**ប្រការ ១ .-**

ធ្វើការកែសម្រួលនិងបំពេញបន្ថែមសមាសភាព និងតួនាទីភារកិច្ចរបស់ក្រុមការងារថ្នាក់ជាតិពហុវិស័យស្តីពីកុមារកំព្រា និងកុមារងាយរងគ្រោះ ( ក ជ ក រ ) ដើម្បីបង្កើនប្រសិទ្ធភាពក្នុងការឆ្លើយតបទៅនឹងស្ថានភាពជាក់ស្តែង ព្រមទាំងដើម្បីលើកកម្ពស់សិទ្ធិទាំងបួនរបស់កុមារកំព្រា កុមារទទួលផលប៉ះពាល់ដោយមេរោគអេដស៍ និងកុមារងាយរងគ្រោះដទៃទៀតនៅកម្ពុជា។

**ប្រការ ២ .-**

ក ជ ក រ ស្ថិតក្រោមការចង្អុលណែនាំផ្ទាល់របស់រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។

**ប្រការ ៣ .-**

ក ជ ក រ មានសមាសភាពដូចខាងក្រោម :

ក- <u>តំណាងរាជរដ្ឋាភិបាលៈ</u>

| | | | |
|---|---|---|---|
| - ឯកឧត្តម | កែវ បូរេន្ទ្រ | ប្រធានក្រុមទីប្រឹក្សាអមក្រសួង និងជាតំណាងរបស់ឯកឧត្តមរដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | ប្រធាន |
| - ឯកឧត្តមវេជ្ជ | តែង គន្ធី | អគ្គលេខាធិការនៃអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ | អនុប្រធាន |
| - ឯកឧត្តម | ប្រាក់ចាន់ធឿន | អគ្គនាយកនៃអគ្គនាយកដ្ឋានបច្ចេកទេសនៃក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | អនុប្រធាន |
| - លោកជំទាវ | ខៀវ បូរី | អគ្គលេខាធិការក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ | អនុប្រធាន |
| - លោកសាស្ត្រាចារ្យវេជ្ជ. | អ៊ុំ សុខុម | អនុប្រធានមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែកនិងកាមរោគនៃក្រសួងសុខាភិបាល | អនុប្រធាន |
| - ឯកឧត្តមបណ្ឌិត | សាន វឌ្ឍនា | អគ្គលេខាធិការរង នៃ ក្រុមប្រឹក្សាស្តារ អភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ(CARD) | អនុប្រធាន |
| - លោកស្រី | ឥម សុផុន | អគ្គនាយករងនៃអគ្គនាយកដ្ឋានបច្ចេកទេសនៃក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | សមាជិក |
| - លោក | អ៊ុំ សុជាន់ណារា | ប្រធាននាយកដ្ឋានសុខុមាលភាពកុមារនៃក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | សមាជិក |
| - លោកស្រី | អ៊ឹង វណ្ណឫទ្ធី | ប្រធាននាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងសមាហរណកម្មជនរងគ្រោះនៃក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | សមាជិក |

- លោកស្រី ប៊ូ ស៊ីថា ប្រធាននាយកដ្ឋានសុខុមាលភាពសង្គម
នៃក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា សមាជិក
- លោក ឡៅ វ៉េង ប្រធាននាយកដ្ឋានសុខុមាលភាពជនពិការ
នៃក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា សមាជិក
- លោក ហ៊ិល ផល ប្រធាននាយកដ្ឋានសុខុមាលភាពមនុស្សចាស់
នៃក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា សមាជិក
- លោក រ៉ិត វ៉ាល់ដា ប្រធានមជ្ឈមណ្ឌលស្តីទីនៃមជ្ឈមណ្ឌលជាតិព្យាបាល
និងស្តារនីតិសម្បទា អ្នកញៀនគ្រឿងញៀននៃក្រសួង
សង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា សមាជិក
- លោក គឹម ថាន្នី អនុប្រធាននាយកដ្ឋាន យុវនីតិសម្បទា
នៃក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា សមាជិក
- លោកស្រី ម៉ៅ សួស្តី អនុប្រធាននាយកដ្ឋានផែនការ ស្ថិតិ និងសរុប
នៃក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា សមាជិក
- លោក ឆើម ឆាត អនុប្រធាននាយកដ្ឋានរដ្ឋបាល នៃក្រសួងធម្មការ
និងសាសនា សមាជិក
- លោកស្រីវេជ្ជ.គូ សុទ្ធា អនុប្រធាននាយកដ្ឋានស្ត្រី និងសុខភាព
នៃក្រសួងកិច្ចការនារី សមាជិក
- លោក យ៉ាវ នី ប្រធានការិយាល័យសហប្រតិបត្តិការនៃនាយកដ្ឋានការងារ
កុមារ នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សមាជិក
- លោក ឃី ឈិត អនុប្រធាននាយកដ្ឋានកិច្ចការព្រហ្មទណ្ឌ
និងអនុគ្រោះទោសនៃក្រសួងយុត្តិធម៌ សមាជិក
- លោក ញាណ សារឿន ប្រធានការិយាល័យអប់រំពិសេស នៃនាយកដ្ឋាន
បឋមសិក្សា នៃក្រសួង អប់រំ យុវជន និងកីឡា សមាជិក
- លោក យ៉ាំ ម៉េងស៊ាន អនុប្រធាននាយកដ្ឋានរដ្ឋបាលមូលដ្ឋាន នៃក្រសួងមហាផ្ទៃ សមាជិក
- កញ្ញា ហួតនន់ សុខាវណ្ណណែត នាយការិយាល័យសុវត្ថិភាពកុមារក្នុងវិស័យទេសចរណ៍
នៃក្រសួងទេសចរណ៍ សមាជិក
- លោកស្រី ជូ ពុទ្ធានី ប្រធាននាយកដ្ឋានផែនការសង្គមកិច្ច និងជាអ្នកគ្រប់គ្រង
កម្មវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ នៃក្រសួងផែនការ សមាជិក
- លោកវេជ្ជ. សយ អ៊ឹង អនុប្រធាននាយកដ្ឋានសុខាភិបាល សន្តិសុខស្បៀង និង
អាហារូបត្ថម្ភ ក្រុមប្រឹក្សាស្តារ អភិវឌ្ឍន៍វិស័យកសិកម្ម
និងជនបទ(CARD) សមាជិក

ខ- តំណាងដៃគូអភិវឌ្ឍន៍

| | | |
|---|---|---|
| - តំណាងមូលនិធិអង្គការសហប្រជាជាតិ ដើម្បីកុមារ | ( UNICEF ) | សមាជិក |
| - តំណាងកម្មវិធីសហប្រជាជាតិរួមគ្នាប្រយុទ្ធ នឹងជំងឺអេដស៍ | ( UNAIDS ) | សមាជិក |
| - តំណាងទីភ្នាក់ងារសហរដ្ឋអាមេរិក ដើម្បីការអភិវឌ្ឍន៍អន្តរជាតិ | (USAIDS) | សមាជិក |
| - តំណាង កម្មវិធីស្បៀងអាហារពិភពលោក | (WFP) | សមាជិក |
| - តំណាង អង្គការ ពលកម្មអន្តរជាតិ | (ILO/IPEC) | សមាជិក |
| - តំណាង អង្គការ អន្តរជាតិទេសន្តរប្រវេសន៍ | (IOM) | សមាជិក |
| - តំណាង ធនាគារអភិវឌ្ឍន៍អាស៊ី | (ADB) | សមាជិក |

គ- តំណាងសង្គមស៊ីវិល

| | | |
|---|---|---|
| - តំណាង សមាគមជាតិកាកបាទក្រហមកម្ពុជា | (CRC) | សមាជិក |
| - តំណាង អង្គការសង្គ្រោះកុមារ | (Save the Children) | សមាជិក |
| - តំណាង អង្គការ ខាណា | (KHANA) | សមាជិក |
| - តំណាង អង្គការ FHI ៣៦០ | (FHI 360) | សមាជិក |
| - តំណាង អង្គការទស្សនៈពិភពលោកកម្ពុជា | (WVC) | សមាជិក |
| - តំណាង អង្គការ អប់រំពិភពលោក | (WE) | សមាជិក |
| - តំណាង អង្គការ Catholic Relief Service | (CRS) | សមាជិក |
| - តំណាង អង្គការ អេស អូ អេស | (SOS) | សមាជិក |
| - តំណាង អង្គការសហការអន្តរជាតិ | (ICC-Project SKY) | សមាជិក |
| - តំណាង គណៈកម្មាធិការសម្របសម្រួលប្រយុទ្ធនឹងជំងឺអេដស៍ | (HACC) | សមាជិក |
| - តំណាង អង្គការ កុមារអាស៊ីអាស្កេការ | (Enfants d' Asie ASPECA) | សមាជិក |
| - តំណាង អង្គការ មិត្តសំឡាញ់ | (Mith Samlanh) | សមាជិក |
| - តំណាង អង្គការសមាគមនារី អភិវឌ្ឍន៍សេដ្ឋកិច្ច និងអនាម័យ | (WOMEN) | សមាជិក |
| - តំណាង អង្គការ ភ្លែនអន្តរជាតិ | (Plan International) | សមាជិក |
| - តំណាង អង្គការការីតាស | (Caritas) | សមាជិក |
| - តំណាង គណៈកម្មាធិការប្រតិបត្តិការដើម្បីកម្ពុជា | (CCC) | សមាជិក |
| - តំណាង អង្គការគណៈកម្មាធិការអង្គការមិនមែនរដ្ឋាភិបាលដើម្បីសិទ្ធិកុមារ | (NGOCRC) | សមាជិក |
| - តំណាង បណ្តាញអ្នកផ្ទុកមេរោគអេដស៍ និងជំងឺអេដស៍នៅកម្ពុជា | (CPN+) | សមាជិក |
| - តំណាង អង្គការ អេវ្រីឆាល | (Every Child) | សមាជិក |
| - តំណាង សមាគមកុមារកម្ពុជាប្រឆាំងទូរ៉ាក្ស និងហិង្សា | (CCASVA) | សមាជិក |
| - តំណាង អង្គការវីនរ៉ុកអន្តរជាតិ | (WINROCK International) | សមាជិក |
| - តំណាង សមាគមចំរើនជាតិ | (NAPA) | សមាជិក |
| - តំណាង មូលនិធិកុមារកម្ពុជា | (Cambodia Child Fund) | សមាជិក |
| - តំណាង សកម្មភាពលើពិការភាព និងអភិវឌ្ឍន៍ | (ADD) | សមាជិក |

- តំណាងអង្គការ ហាកា (HAGAR) សមាជិក
- តំណាង សម្ព័ន្ធអង្គការមិនមែនរដ្ឋាភិបាលប្រឆាំងការជួញដូរកុមារនៅកម្ពុជា (Cambodia Acts) សមាជិក
- តំណាង អង្គការលើកកម្ពស់សុខភាព និងអភិវឌ្ឍន៍ (HEAPDO) សមាជិក
- តំណាង អង្គការមូលនិធិសិទ្ធិកុមារ (CRF) សមាជិក
- តំណាង អង្គការមាគ៌ានៃវឌ្ឍនភាព (Pathways to Development ) សមាជិក

**ប្រការ ៤ ៈ-**

តួនាទី ភារកិច្ចទទួលខុសត្រូវរបស់ ក ជ ក រ មានដូចតទៅ ៖

- ជំរុញ និងសម្របសម្រួលការអនុវត្តផែនការសកម្មភាពជាតិ សម្រាប់កុមារកំព្រា កុមារទទួលផលប៉ះពាល់ដោយមេរោគអេដស៍ និងកុមារងាយរងគ្រោះដទៃទៀតក្នុងប្រទេសកម្ពុជា (២០១២-២០១៥) ព្រមទាំងតាមដានវាយតម្លៃការអនុវត្ត រកឃើញភាពខ្វះចន្លោះ កំណត់បញ្ហាអាទិភាព និងផ្តល់អនុសាសន៍ ដើម្បីធ្វើការកែសម្រួលតាមការចាំបាច់ សំដៅធ្វើឲ្យប្រសើរឡើង ដល់ការឆ្លើយតបនៅថ្នាក់ជាតិ ដោយអនុវត្តនិយមន័យទូលំទូលាយរបស់កុមារកំព្រានិងកុមារងាយរងគ្រោះ ដូចបានកំណត់នៅក្នុងបទដ្ឋាននិងគោលការណ៍ណែនាំសម្រាប់ការថែទាំ ការគាំទ្រ និងការការពារ ចំពោះកុមារកំព្រា និងកុមារងាយរងគ្រោះ ។
- ជំរុញ និងសម្របសម្រួលកិច្ចសហការ ការពិភាក្សា និងការផ្លាស់ប្តូរព័ត៌មានរវាងស្ថាប័នសំខាន់ៗរបស់រាជរដ្ឋាភិបាល អង្គការមិនមែនរដ្ឋាភិបាល និងយន្តការពាក់ព័ន្ធដែលធ្វើការជាមួយកុមារកំព្រា កុមារទទួលផលប៉ះពាល់ដោយមេរោគអេដស៍ និងកុមារងាយរងគ្រោះដទៃទៀត ។
- តាមដាន វាយតម្លៃស្ថានភាពកុមារកំព្រា កុមារទទួលផលប៉ះពាល់ដោយមេរោគអេដស៍ និងកុមារងាយរងគ្រោះដទៃទៀត និង ផ្តល់អនុសាសន៍ ដល់ការធ្វើសកម្មភាពជាក់ស្តែងដើម្បីដោះស្រាយបញ្ហា និងបំពេញការខ្វះខាតទាក់ទងដល់ការតាក់តែង និងអនុវត្តគោលនយោបាយ ក្របខណ្ឌច្បាប់ បទដ្ឋាន គោលការណ៍ណែនាំ និងការផ្តល់សេវាដល់កុមារកំព្រា កុមារទទួលផលប៉ះពាល់ដោយមេរោគអេដស៍ និងកុមារងាយរងគ្រោះដទៃទៀត។
- ផ្តល់ការគាំទ្រជាប្រចាំផ្នែកបច្ចេកទេសដល់ក្រុមការងារពហុវិស័យស្តីពីកុមារកំព្រា និងកុមារងាយរងគ្រោះខេត្តអាទិភាពដែលបានបង្កើតរួច។
- ទាក់ទាញការគាំទ្រ ផ្តល់យោបល់ និងសម្របសម្រួលការផ្តល់សេវាប្រកបដោយគុណភាពដល់កុមារកំព្រា កុមារទទួលផលប៉ះពាល់ដោយមេរោគអេដស៍ និងកុមារងាយរងគ្រោះដទៃទៀតនៅតាមគ្រួសារ និងសហគមន៍នៅថ្នាក់ជាតិ រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់។
- ផ្តល់យោបល់ និងយោបល់ត្រឡប់វិញដល់ក្រសួង ស្ថាប័ន អង្គការ និងយន្តការពាក់ព័ន្ធនានា នៅថ្នាក់ជាតិដើម្បីជំរុញតាមដាន ការអនុវត្តផែនការយុទ្ធសាស្ត្រទាំងឡាយ ដែលទាក់ទងដល់កុមារកំព្រា កុមារទទួលផលប៉ះពាល់ដោយមេរោគអេដស៍ និងកុមារងាយរងគ្រោះដទៃទៀត ដូចជាផែនការយុទ្ធសាស្ត្រជាតិទូលំទូលាយនិងពហុវិស័យឆ្លើយតបការរីករាលដាលមេរោគអេដស៍ និងជំងឺអេដស៍លើកទី៣(២០១២-២០១៥) យុទ្ធសាស្ត្រជាតិគាំពារសង្គម សម្រាប់ជនក្រីក្រ និងជនងាយរងគ្រោះ(២០១១-២០១៥) កម្មវិធីការងាររបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា សម្រាប់ឆ្នាំ២០០៨-២០១៣ គោលនយោបាយ និងបទដ្ឋានអប្បបរមា

ផលប៉ះពាល់ដោយមេរោគអេដស៍ និងកុមារងាយរងគ្រោះដទៃទៀត។

- ពង្រីកសេវាគ្រប់ដណ្ដប់របស់ខ្លួនដល់រាជធានីនិងបណ្ដា ខេត្តអាទិភាពដទៃទៀត ផ្អែកលើធនធានដែលមាន និងសេចក្ដីត្រូវការជាក់ស្ដែងរបស់កុមារកំព្រា កុមារទទួលផលប៉ះពាល់ដោយមេរោគអេដស៍ និងកុមារងាយរងគ្រោះដទៃទៀត និងបន្ទាប់ពីបានពិគ្រោះយោបល់ជាមួយក្រសួង ស្ថាប័ន និងអង្គការពាក់ព័ន្ធ។
- ជំរុញតាមដានការអនុវត្តបទដ្ឋាន និងគោលការណ៍ណែនាំសម្រាប់ការថែទាំ ការគាំទ្រ និងការការពារចំពោះកុមារកំព្រា និងកុមារងាយរងគ្រោះ និងប្រកាសស្ដីពីនីតិវិធីអនុវត្ត គោលនយោបាយស្ដីពីការថែទាំជំនួសចំពោះកុមារ។
- គាំទ្រដល់យន្តការថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ក្នុងការធ្វើអត្តសញ្ញាណកម្មកុមារកំព្រា កុមារទទួលផលប៉ះពាល់ដោយមេរោគអេដស៍ និងកុមារងាយរងគ្រោះដទៃទៀត។
- ចងក្រងបទពិសោធន៍ល្អៗក្នុងការផ្ដល់សេវាដល់កុមារកំព្រា កុមារទទួលផលប៉ះពាល់ដោយមេរោគអេដស៍ និងកុមារងាយរងគ្រោះដទៃទៀត និងផ្សព្វផ្សាយបទពិសោធន៍ទាំងនេះជូនដល់ដៃគូពាក់ព័ន្ធ។
- សម្របសម្រួលដល់ការកៀរគរថវិកាសម្រាប់ផ្ដល់សេវាដល់កុមារកំព្រា កុមារទទួលផលប៉ះពាល់ដោយមេរោគអេដស៍ និងកុមារងាយរងគ្រោះដទៃទៀត ពិសេសពេលមានការខ្វះខាតថវិកា។
- ធ្វើរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំ ជូនឯកឧត្ដមរដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។

**ប្រការ ៥ .–**

ក្រៅពីចូលរួមអនុវត្ត ភារកិច្ចទទួលខុសត្រូវរួមរបស់ **ក ជ ក រ** ដូចមានចែងក្នុងប្រការ៤ សមាជិក **ក ជ ក រ** ម្នាក់ៗ មានភារកិច្ចដោយឡែកដូចតទៅ ៖

- តាមដានជំរុញការអនុវត្តផែនការយុទ្ធសាស្ត្រនិងកម្មវិធីការងាររបស់ក្រសួង ស្ថាប័ន និងអង្គការ របស់ខ្លួន ដែលពាក់ព័ន្ធ នឹងកុមារកំព្រា កុមារទទួលផលប៉ះពាល់ដោយមេរោគអេដស៍ និងកុមារងាយរងគ្រោះដទៃទៀត ដើម្បីរួមចំណែក អនុវត្តដោយជោគជ័យ នូវផែនការសកម្មភាពជាតិសម្រាប់កុមារកំព្រា កុមារទទួលផលប៉ះពាល់ដោយមេរោគអេដស៍និងកុមារងាយរងគ្រោះ ដទៃទៀត(២០១២-២០១៥)។
- រាយការណ៍ និងផ្ដល់យោបល់ជូនថ្នាក់ដឹកនាំ និងមន្ត្រីពាក់ព័ន្ធរបស់ក្រសួង ស្ថាប័ន និងអង្គការរបស់ខ្លួនអំពីលទ្ធផលការងារ បញ្ហាប្រឈម ការវាយតម្លៃ និងអនុសាសន៍ផ្សេងៗរបស់ **ក ជ ក រ** ។
- ផ្ដល់យោបល់ផ្នែកបច្ចេកទេសដល់ក្រសួងស្ថាប័ន និងអង្គការរបស់ខ្លួន លើរាល់បញ្ហាដែលទាក់ទងដល់កុមារកំព្រា កុមារទទួលផលប៉ះពាល់ដោយមេរោគអេដស៍ និងកុមារងាយរងគ្រោះដទៃទៀត រួមទាំងការត្រៀមរៀបចំ និងការឆ្លើយតបទាន់ពេលវេលា ចំពោះគ្រោះអាសន្នផ្សេងៗ ។
- រាយការណ៍ជូន **ក ជ ក រ** អំពីលទ្ធផលការងារ បញ្ហាប្រឈម និងអនុសាសន៍នានារបស់ក្រសួង ស្ថាប័ន និងអង្គការរបស់ខ្លួន លើរាល់បញ្ហាដែលទាក់ទងដល់កុមារកំព្រា កុមារទទួលផលប៉ះពាល់ដោយមេរោគអេដស៍ និងកុមារងាយរងគ្រោះ ដទៃទៀត។

- ចូលរួមរាល់កិច្ចប្រជុំរបស់ ក ជ ក វ ដោយស្មារតីទទួលខុសត្រូវ។
- អនុវត្តភារកិច្ចដទៃទៀតតាមការចាត់តាំងរបស់ប្រធាន ក ជ ក វ ។

**ប្រការ ៦ ៖—**

ក ជ ក វ មានលេខាធិការដ្ឋានស្ថិតនៅក្នុងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។ លេខាធិការដ្ឋាន ក ជ ក វ ស្ថិតក្រោមការដឹកនាំផ្ទាល់របស់ប្រធាន ក ជ ក វ ។

លេខាធិការដ្ឋាន ក ជ ក វ មានសមាសភាពដូចខាងក្រោម:

- លោក ខ្លូង ពិចិត្រ ប្រធានការិយាល័យកិច្ចការសេវាកុមារសហគមន៍នៃក្រសួងសង្គមកិច្ច អតីតយុទ្ធជននិងយុវនីតិសម្បទា ជាមន្ត្រីសម្របសម្រួលកម្មវិធី ក ជ ក វ
- លោកវេជ្ជ. អ៊ុកម៉ារឌី អនុប្រធាននាយកដ្ឋាន បង្ការ ថែទាំ និងគាំទ្រ នៃអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ជាជំនួយការបច្ចេកទេសផ្នែកសុខភាពសាធារណៈ
- លោកស្រី កែវ រ៉ាវី មន្ត្រីនាយកដ្ឋានសុខុមាលភាពកុមារ នៃក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ជាមន្ត្រីរដ្ឋបាល និងហិរញ្ញវត្ថុ
- លោក សោម ភារៈ អនុប្រធាននាយកដ្ឋាន អតីតយុទ្ធជន នៃក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ជាមន្ត្រីបញ្ចូលទិន្នន័យគេហទំព័រ ក ជ ក វ
- លោក អេង សច្ចៈ មន្ត្រីនាយកដ្ឋាន យុវនីតិសម្បទា នៃក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ជាមន្ត្រីប្រមូលទិន្នន័យគេហទំព័រ ក ជ ក វ ។

លេខាធិការដ្ឋាន ក ជ ក វ មានភារៈកិច្ចជាអាទិ៍ ៖

- គ្រប់គ្រងលិខិត ចេញ ចូល របស់ ក ជ ក វ ។
- រៀបចំ ចូលរួម និងធ្វើរបាយការណ៍រាល់កិច្ចប្រជុំរបស់ ក ជ ក វ គណៈកម្មាធិការប្រតិបត្តិ ក ជ ក វ និងអនុគណៈកម្មាធិការជំនាញរបស់ ក ជ ក វ ។
- រៀបចំសេចក្តីព្រាងរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំរបស់ ក ជ ក វ និងរបស់គណៈកម្មាធិការប្រតិបត្តិ ក ជ ក វ និងលើកទិសដៅអនុវត្តបន្ត។
- រៀបចំសេចក្តីព្រាងផែនការសកម្មភាព និងផែនការថវិកាប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំរបស់ ក ជ ក វ ។
- គ្រប់គ្រង និងដំណើរការគេហទំព័ររបស់ ក ជ ក វ ។
- គ្រប់គ្រងសម្ភារៈបរិក្ខាររបស់លេខាធិការដ្ឋាន ក ជ ក វ ។
- បំពេញភារកិច្ចផ្សេងៗទៀតតាមការចាត់តាំងរបស់ប្រធាន ក ជ ក វ ។

**ប្រការ ៧ ៖—**

ក ជ ក វ ត្រូវបង្កើតគណៈកម្មាធិការប្រតិបត្តិ ព្រមទាំងអនុគណៈកម្មាធិការជំនាញ និងក្រុមការងារផ្សេងៗ ដើម្បីជួយការងាររបស់ខ្លួន។

ដោយប្រធានក ជ ក រ ឬដោយអនុប្រធានគ ជ ក រ ដែលត្រូវបានប្រគល់សិទ្ធិពេលប្រធានក ជ ក រ អវត្តមាន ។ សមាជិក ក ជ ក រ ដែលមិនអាច ចូលរួមប្រជុំបាន ត្រូវចាត់តាំងឲ្យបានទៀងទាត់នូវអ្នកចូលរួមប្រជុំជំនួស ផ្អែកតាមបញ្ជីឈ្មោះ ដែលក្រសួង ស្ថាប័ន អង្គការ នីមួយៗបានផ្ញើជាមុនមកលេខាធិការដ្ឋាន ក ជ ក រ ។ អ្នកចូលរួមប្រជុំជំនួសត្រូវមាន ការយល់ដឹងពីបញ្ហាពាក់ព័ន្ធ នឹងកិច្ចប្រជុំ។

**ប្រការ ៩ ៖-**

បន្ទាប់ពីបានពិគ្រោះយោបល់ជាមួយអនុប្រធានទាំងប្រាំ ប្រធាន ក ជ ក រ អាចអញ្ជើញតំណាងក្រសួង ស្ថាប័ន និងអង្គការពាក់ព័ន្ធដទៃទៀតចូលរួមកិច្ចប្រជុំ ក ជ ក រ តាមការចាំបាច់។

**ប្រការ ១០ ៖-**

អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារថ្នាក់រាជធានី ខេត្ត គ្រប់នាយកដ្ឋានពាក់ព័ន្ធ របស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រាជធានី ខេត្ត ត្រូវសម្របសម្រួលឲ្យមានការផ្លាស់ប្តូរព័ត៌មាន បទពិសោធន៍ពីគ្នាទៅវិញទៅមក និងអញ្ជើញ ក ជ ក រ ចូលរួមរាល់សកម្មភាព របស់ខ្លួនដែលពាក់ព័ន្ធនឹងកុមារកំព្រា កុមារទទួលផលប៉ះពាល់ដោយមេរោគអេដស៍និងកុមារងាយរងគ្រោះដទៃទៀត។

នាយកដ្ឋានផែនការ ស្ថិតិ និងសរុបរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ត្រូវដាក់ បញ្ចូលរាល់សកម្មភាពរបស់ក ជ ក រ នៅក្នុងរបាយការណ៍របស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា។

**ប្រការ ១១ ៖-**

សមាជិកភាពរបស់ ក ជ ក រ និងលេខាធិការដ្ឋាន ក ជ ក រ អាចត្រូវបានពិនិត្យកែសម្រួលឡើងវិញតាមការចាំបាច់ ដើម្បីធានា នូវប្រសិទ្ធិភាពក្នុងការបំពេញភារកិច្ចរបស់ក ជ ក រ។

**ប្រការ ១២ ៖-**

ក ជ ក រ ត្រូវកំណត់បន្ថែមអំពីរបៀបរបបធ្វើការងាររបស់ខ្លួន។

**ប្រការ ១៣ ៖-**

ប្រកាសលេខ ១២២៨ ស.អ.យ ចុះថ្ងៃទី ០៤ ខែធ្នូ ឆ្នាំ២០០៩ របស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា ត្រូវចាត់ទុកជាមោឃៈ។

**ប្រការ ១៤ .-**

ខុទ្ទកាល័យរដ្ឋមន្ត្រី អគ្គនាយកដ្ឋានកិច្ចការរដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយកដ្ឋានបច្ចេកទេស នាយកដ្ឋានសុខុមាលភាពកុមារ នាយកដ្ឋានសុខុមាលភាពសង្គម នាយកដ្ឋានយុវនីតិសម្បទា នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងសមាហរណកម្មជនរងគ្រោះ នាយកដ្ឋានសុខុមាលភាពជនពិការ នាយកដ្ឋានសុខុមាលភាពមនុស្សចាស់ នាយកដ្ឋានអតីតយុទ្ធជន នាយកដ្ឋានផែនការ ស្ថិតិ និងសរុប ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី ដូចមានឈ្មោះក្នុងប្រការ៣ និងប្រការ៦ មានភារកិច្ចអនុវត្តឲ្យមានប្រសិទ្ធភាពតាមប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។៚

រដ្ឋមន្ត្រី

**អ៊ិត សំហេង**

<u>ចម្លងជូន:</u>

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ លោកជំទាវឧបនាយករដ្ឋមន្ត្រី **ម៉ែន សំអន**
- គេប់ថ្នាក់ដឹកនាំ ក្រសួងសង្គមកិច្ច អតីតយុទ្ធជននិងយុវនីតិសម្បទា
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ
- គ្រប់នាយកដ្ឋាន មន្ទីរ និងអង្គភាពក្រោមឱវាទរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួងស្ថាប័ន និងអង្គការពាក់ព័ន្ធ
- ដូចប្រការ ១៤
- ឯកសារ -កាលប្បវត្តិ